**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**
សំណុំរឿងព្រហ្មទណ្ឌលេខ៦៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១
សំណុំរឿងស៊ើបសួរលេខ៥០៧ប្រ.ក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ៤៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២
កាលបរិច្ឆេទសវនាការថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២
កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២
**សាលក្រមលេខ: ២៨១/២៦ "ឈ"**
ចុះថ្ងៃពុធ ៤រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥
ត្រូវនឹងថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រះសីហនុ

**បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តព្រះសីហនុ**
**ដោយមានសមាសភាពដូចតទៅ**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៦៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ លើជនជាប់ចោទ៖

១.ឈ្មោះ [redacted] **រិទ្ធី ហៅ ស្ទិត** ភេទប្រុស កើតឆ្នាំ១៩៩៤ ជនជាតិខ្មែរ មុខរបរកម្មករសំណង់ មានទីកន្លែងកំណើតនៅភូ[redacted]ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្នភូមិអូរក្រោះ ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានប្រពន្ធឈ្មោះ [redacted]កែវ មានកូនចំនួន ០២នាក់ ឪពុកឈ្មោះ[redacted]ប្អូន "រ" ម្តាយឈ្មោះ[redacted]នី "រ" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **"គ្មាន"**។ **(ក្រៅឃុំ ៖ សាលដីកាលេខ ៣៨ "V" ចុះថ្ងៃទី២៦ខែមករា ឆ្នាំ២០២២ របស់តុលាការកំពូល)**

២.ឈ្មោះ [redacted]**សុខុម** ភេទប្រុស កើតឆ្នាំ១៩៩៥ ជនជាតិខ្មែរ មុខរបរ កម្មករសំណង់ មានទីកន្លែងកំណើតនៅ[redacted] ខេត្តស្វាយរៀង មានទីលំនៅបច្ចុប្បន្ននៅភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នៅលីវ ឪពុកឈ្មោះ[redacted]**ខេន** "រ" ម្តាយឈ្មោះ[redacted] **សួន** "រ" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **"គ្មាន"**។ **(ក្រៅឃុំ ៖ សាលដីកាលេខ ៣៨ "V" ចុះថ្ងៃទី២៦ខែមករា ឆ្នាំ២០២២ របស់តុលាការកំពូល)**

៣.ឈ្មោះ[redacted] **ឌៀ** ភេទប្រុស កើតឆ្នាំ១៩៨៧ ជនជាតិខ្មែរ មុខរបរ អ្នកចាំដី មានទីកន្លែងកំណើត[redacted] ខេត្តស្វាយរៀង មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានប្រពន្ធឈ្មោះ **ភ័ណ្ឌ** មានកូនចំនួន ០២នាក់ ឪពុកឈ្មោះ **ឭ** "រ" ម្តាយឈ្មោះ **ថៃ** "ស" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **"គ្មាន"**។ **(ក្រៅឃុំ ៖ សាលដីកាលេខ ៣៨ "V" ចុះថ្ងៃទី២៦ខែមករា ឆ្នាំ២០២២ របស់តុលាការកំពូល)**



Scanned with CamScanner

៤.ឈ្មោះ [redacted] **ភីរុណា** ភេទប្រុស កើតឆ្នាំ១៩៧២ ជនជាតិខ្មែរ មុខរបរ កម្មករសំណង់ មានទីកន្លែងកំណើតនៅ [redacted]រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ននៅភូមិថ្នល់ទក្សិណ ក្រុងតាខ្មៅ ខេត្តកណ្តាល មានប្រពន្ធឈ្មោះ [redacted] សាវីន មានកូនចំនួន ០៣នាក់ ឪពុកឈ្មោះ [redacted] សារ៉េត "ស" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **"គ្មាន"**។ **(ក្រៅឃុំ ៖ សាលដីកាលេខ ៣៨ "V" ចុះថ្ងៃទី២៦ខែមករា ឆ្នាំ២០២២ របស់តុលាការកំពូល)**

៥.ឈ្មោះ [redacted] **សុភ័ណ្ឌ** ភេទប្រុស កើតឆ្នាំ១៩៨០ ជនជាតិខ្មែរ មុខរបរមេការសំណង់ មានទីកន្លែងកំណើតនៅ [redacted] ខេត្តកណ្តាល មានអាសយដ្ឋាននៅភូមិតារាងបាល់ សង្កាត់គយត្របែក ក្រុងស្វាយរៀង ខេត្តស្វាយរៀង។ **(កាន់អត្តសញ្ញាណបណ្ណលេខ ០៩០៥៩២០៣១៧ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣)**

ជាប់ចោទពីបទ ៖ **ជនប្រើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅចំណុចភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា២៥៣ នៃច្បាប់ភូមិបាល និងមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **រិទ្ធី ហៅ ស្ទិត**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **ឌៀ** និងឈ្មោះ [redacted] **ភីរុណា**។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ១០១០ អ.យ.ង/២១ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

បានឃើញ ដីកាដំណោះស្រាយលេខ៦៤២៩ ត.ព/២១ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ។

បានឃើញ ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ៤៩៥ ត.ព.រ/២២ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ។

## អង្គហេតុដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យមានដូចតទៅ

កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ មានករណី **ប្រើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងធ្វើឱ្យខូចខាតដោយចេតនា** នៅចំណុចភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដោយឃាត់ខ្លួនជនសង្ស័យចំនួន ០៤នាក់ រួមមានឈ្មោះ [redacted] **រិទ្ធី ហៅ ស្ទិត** ភេទប្រុស, ឈ្មោះ [redacted] **សុខុម** ភេទប្រុស, ឈ្មោះ [redacted] **ឌៀ** ភេទប្រុស និងឈ្មោះ [redacted] **ភីរុណា** ភេទប្រុស ដោយពួកគេ និងបក្ខពួក ព្រមទាំងឈ្មោះ [redacted] **សុភ័ណ្ឌ**, ឈ្មោះ [redacted] **ពុទ្ធា** និងឈ្មោះ [redacted] **ណាន** បានធ្វើសកម្មភាពយកដែកទៅអង្រួនទ្វាររបងរបស់ក្រុមហ៊ុនហ្វូហាយរហូតដល់សោរទ្វាត្រូវបើកបន្ទាប់មកក៏នាំគ្នាចូលទៅក្នុងទីតាំងដីរបស់ក្រុមហ៊ុនដែលមានបណ្ណកម្មសិទ្ធិលេខ ព.ន០០១៦០៩, លេខព.ន ០០១៦០៥, លេខ ព.ន ០០១៦០០ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ១៩៩៦។ ក្រោយពីឃើញទ្វាររបងត្រូវបើក ឈ្មោះ [redacted] **កញ្ញារិទ្ធ** ភេទប្រុស ជាសន្តិសុខក្រុមហ៊ុន និង ជាអ្នកឃាមដី នៅទីនោះបានធ្វើការឃាត់ជនសង្ស័យ ប៉ុន្តែពួកគេមិនស្តាប់ក៏ឈ្មោះ [redacted] **កញ្ញារិទ្ធ** បានរាយការណ៍ទៅសមត្ថកិច្ចឱ្យចុះអន្តរាគមន៍ និងឃាត់ខ្លួនបានជនសង្ស័យទាំង ០៤នាក់ខាងលើ ដោយឡែកជនសង្ស័យផ្សេងទៀតបានរត់គេចខ្លួនបាត់។

## នាពេលសវនាការ

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] **រិទ្ធី ហៅ ស្ទិត** បានឆ្លើយថា ៖ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ ប្រហែលម៉ោង ០២ រសៀល ឈ្មោះ [redacted] **សោភ័ណ្ឌ** បានទូរស័ព្ទមកខ្លួនដើម្បីឱ្យខ្លួនទៅចាំដីឱ្យឈ្មោះ [redacted] **ហេង** ចំនួន ០៣ថ្ងៃ ដោយឱ្យថ្លៃឈ្នួលក្នុងមួយថ្ងៃ ៤០០០០រៀល ហើយខ្លួន និងឈ្មោះ [redacted] **ឌៀ** បានជិះម៉ូតូទៅទីតាំងដីកើតហេតុ បានជួបអ៊ុំប្រុសម្នាក់ (មិនស្គាល់ឈ្មោះ) ដែលគាត់ឈរនៅមុខទ្វារចាំទទួលខ្លួន ហើយពួកខ្លួនក៏បាននាំគ្នាដើរទៅក្នុងទីតាំងដី ហើយខ្លួនបានឱ្យឈ្មោះ [redacted] **ឌៀ** ត្រឡប់ទៅវិញនៅសល់តែខ្លួន និងអ៊ុំប្រុស ព្រមទាំងប្រពន្ធរបស់គាត់។ វេលាម៉ោងប្រហែលជា ០៦ល្ងាច មានបុគ្គលិកក្រុមហ៊ុនចំនួន ២០នាក់ បានដល់ទីតាំងដីដែរ ហើយបានដកយកសោទ្វាររបងពីអ៊ុំប្រុស និងដកយកទូរស័ព្ទដៃខ្លួន និងអ៊ុំប្រុសព្រមទាំងឱ្យពួកខ្លួនរើចេញពីទីតាំងដីនោះ។ លុះព្រឹកឡើងប្រហែលជា



Scanned with CamScanner

ម៉ោង៦ អ៊ុំប្រុស និង ប្រពន្ធរបស់គាត់ បានរើចេញចំណែកខ្លួននៅក្នុងទីតាំងដីដដែល។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង០៦ និង ៣០នាទីព្រឹក ឈ្មោះ [redacted] **សាភ័ណ្ឌ** បានទូរស័ព្ទមកខ្លួនកុំឱ្យចេញពីទីតាំងដី ចាំគាត់មកដល់សិន ព្រោះគាត់មកដល់ឥឡូវហើយ។ បន្ទាប់មកខ្លួនក៏ទូរស័ព្ទទៅឈ្មោះ [redacted] **ឌៀ** ឱ្យមកដើម្បីបានជាគ្នាហើយឈ្មោះ [redacted] **ឌៀ** និងឈ្មោះ [redacted] **សុខុម** ក៏បានជិះម៉ូតូមកដល់។ ម៉ោងប្រហែល ០៧ព្រឹក ឈ្មោះ [redacted] **សុភ័ណ្ឌ**, ឈ្មោះ [redacted] **ភីរុណ**, ឈ្មោះ [redacted] **ពុទ្ធា** (ជិះជាមួយគ្នា) និងឈ្មោះ ចំណាន (ជិះម្នាក់ឯង) ក៏បានជិះរថយន្តមកដល់ទីតាំងដីហើយបានសុំឱ្យបុគ្គលិកក្រុមហ៊ុនបើកទ្វារតែបុគ្គលិកក្រុមហ៊ុនថាចាំសុំមេគេសិន។ បន្ទាប់មកឈ្មោះ [redacted] **ភីរុណ** បានទៅអង្រួនទ្វារបង់រហូតដល់របើកហើយពួកខ្លួនទាំង ០៧នាក់ រួមមាន ខ្លួន, ឈ្មោះ [redacted] **ឌៀ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **សុភ័ណ្ឌ** ឈ្មោះ [redacted] **ភីរុណ**ឈ្មោះ [redacted] **ពុទ្ធា** និងឈ្មោះ **ចំណាន** បានដើរចូលទៅខាងក្នុង ហើយឈ្មោះ [redacted] **សុភ័ណ្ឌ** សួរទៅបុគ្គលិកក្រុមហ៊ុន ហេតុអ្វីបានជាច្រានក្រុមការងាររបស់ខ្លួនតែបុគ្គលិកក្រុមហ៊ុនមិនតបទេ។ វេលាម៉ោងប្រហែល ០៩ ព្រឹកឈ្មោះ [redacted] **សុភ័ណ្ឌ**, ឈ្មោះ [redacted] **ពុទ្ធា** និងឈ្មោះ **ចំណាន** បានបើករថយន្តចេញទៅវិញ។ ក្រោយមកមេការរបស់ក្រុមហ៊ុនបានមកដល់ហើយស្តីឱ្យពួកខ្លួនទាំង ០៤នាក់ និងបានបុគ្គលិកក្រុមហ៊ុននៅចាំឃាមពួកខ្លួនមិនឱ្យទៅណា។ លុះដល់ម៉ោង ១០ ក៏មានសមត្ថកិច្ចមកដល់ឃាត់ខ្លួន។

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] **សុខុម** បានឆ្លើយថា ៖ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ ប្រហែលម៉ោង ០៦ និង ៣០ នាទីព្រឹក ឈ្មោះ [redacted] **សុភ័ណ្ឌ** បានទូរស័ព្ទមកឈ្មោះ [redacted] **ឌៀ** ដើម្បីឱ្យខ្លួនទៅចាំដីឱ្យឈ្មោះ [redacted] **ហេង** ចំនួន ០៣ ថ្ងៃ ហើយខ្លួន និងឈ្មោះ [redacted] **ឌៀ** បានជិះម៉ូតូទៅទីតាំងដីឃើញទ្វារបងចំហរ ទើបពួកខ្លួនជិះម៉ូតូចូលតែបុគ្គលិកក្រុមហ៊ុន មិនឱ្យចូល និងបានឱ្យពួកខ្លួនចេញមកក្រៅ។ ប្រហែលជាម៉ោង០៨ ឈ្មោះ [redacted] **សុភ័ណ្ឌ** ឈ្មោះ [redacted] **ភីរុណ** ឈ្មោះ [redacted] **ពុទ្ធា** និងឈ្មោះ **ចំណាន** មកដល់ហើយឈ្មោះ [redacted] **សុភ័ណ្ឌ** បានប្រើឈ្មោះ [redacted] **ភីរុណ** ទៅអង្រួនទ្វារបង់រហូតដល់របើក ហើយពួកខ្លួនទាំង ០៧នាក់រួមមាន ខ្លួន, ឈ្មោះ [redacted] **ឌៀ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **សុភ័ណ្ឌ**, ឈ្មោះ [redacted] **ភីរុណ**, ឈ្មោះ [redacted] **ពុទ្ធា** និងឈ្មោះ **ចំណាន** បានដើរចូលទៅខាងក្នុង។ វេលាម៉ោងប្រហែល ០៩ ព្រឹក ឈ្មោះ [redacted] **សុភ័ណ្ឌ**, ឈ្មោះ [redacted] **ពុទ្ធា** និងឈ្មោះ **ចំណាន** បានបើករថយន្តចេញទៅវិញ ដោយឈ្មោះ [redacted] **ភីរុណ** បានប្រើឱ្យខ្លួន និងឈ្មោះ [redacted] **ឌៀ** ទៅទិញបាយ។ ពេលត្រឡប់មកវិញក៏ត្រូវបុគ្គលិកក្រុមហ៊ុននៅចាំឃាមពួកខ្លួនមិនឱ្យទៅណា ហើយក៏មានសមត្ថកិច្ចមកដល់ឃាត់ខ្លួន។

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] **ឌៀ** បានឆ្លើយថា ៖ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ ប្រហែលម៉ោង ០៨យប់ឈ្មោះ [redacted] **សុភ័ណ្ឌ** បានទូរស័ព្ទមកខ្លួនដើម្បីទៅចាំដីឱ្យឈ្មោះ [redacted] **ហេង** ចំនួន ០៣ថ្ងៃ ដោយឱ្យថ្លៃឈ្នួលក្នុងមួយថ្ងៃ ៤០០០០រៀល ហើយខ្លួន និងឈ្មោះ [redacted] **រិទ្ធី** ហៅ **ស្វិត** បានជិះម៉ូតូទៅទីតាំងដីកើតហេតុ និងបានជួបអ៊ុំប្រុសម្នាក់ (មិនស្គាល់ឈ្មោះ) ដែលគាត់ឈរនៅមុខទ្វារចាំទទួលខ្លួន ហើយពួកខ្លួននាំគ្នាដើរទៅក្នុងទីតាំងដី បន្ទាប់មកខ្លួនក៏ត្រឡប់ទៅវិញនៅសល់តែឈ្មោះ [redacted] **រិទ្ធី** ហៅ **ស្វិត** និងអ៊ុំប្រុស ព្រមទាំងប្រពន្ធរបស់គាត់។ នៅម៉ោងប្រហែលជា ០៨យប់ឈ្មោះ [redacted] **រិទ្ធី** ហៅ **ស្វិត** បានទូរស័ព្ទហៅខ្លួន និងឈ្មោះ [redacted] **សុខុម** ឱ្យមកទីតាំងដីម្តងទៀតតែពេលមកដល់បុគ្គលិកក្រុមហ៊ុនមិនឱ្យពួកខ្លួនចូលទេ។ លុះព្រឹកឡើងវេលាម៉ោង០៧ ឈ្មោះ [redacted] **សុភ័ណ្ឌ** បានទូរស័ព្ទមកខ្លួនឱ្យមកទីតាំងដី ពេលទៅដល់ខ្លួនឃើញទ្វារចំហរ ពួកខ្លួនក៏ជិះម៉ូតូចូល តែត្រូវបុគ្គលិកក្រុមដេញពួកខ្លួនចេញមកក្រៅ។ ម៉ោងប្រហែល០៨ ព្រឹក ឈ្មោះ [redacted] **សុភ័ណ្ឌ** ឈ្មោះ [redacted] **ភីរុណ** ឈ្មោះ [redacted] **ពុទ្ធា** (ជិះជាមួយគ្នា) និងឈ្មោះ **ចំណាន** (ជិះម្នាក់ឯង) ក៏បានជិះរថយន្តមកដល់ទីតាំងដី ហើយបានសុំបុគ្គលិកក្រុមហ៊ុនបើកទ្វារតែគេថាចាំសុំមេសិន។ បន្ទាប់មកឈ្មោះ [redacted] **ភីរុណ** បានទៅអង្រួន ទ្វារបង់រហូតដល់របើក ហើយពួកខ្លួនទាំង ០៧នាក់រួមមាន ខ្លួន និងឈ្មោះ [redacted] **ឌៀ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **សុភ័ណ្ឌ**, ឈ្មោះ [redacted] **ភីរុណ**, ឈ្មោះ [redacted] **ពុទ្ធា** និងឈ្មោះ **ចំណាន** ក៏បានដើរចូលទៅខាងក្នុង ហើយឈ្មោះ [redacted] **សុភ័ណ្ឌ** សួរទៅបុគ្គលិកក្រុមហ៊ុន ហេតុអ្វីបានជាច្រានក្រុមការងាររបស់ខ្លួនតែបុគ្គលិកក្រុមហ៊ុនមិនតបទេ។ ម៉ោងប្រហែល ០៩ព្រឹក ឈ្មោះ [redacted] **សុភ័ណ្ឌ**, ឈ្មោះ [redacted] **ពុទ្ធា** និងឈ្មោះ **ចំណាន** បានបើករថយន្តចេញទៅវិញ ។ ក្រោយមកមេការរបស់បុគ្គលិកក្រុមហ៊ុនបានមកដល់ ស្តីឱ្យពួកខ្លួនទាំង ០៤នាក់ និងបានឱ្យបុគ្គលិកក្រុមហ៊ុន នៅចាំឃាមពួកខ្លួនមិនឱ្យទៅណា ហើយក៏មានសមត្ថកិច្ចមកដល់ឃាត់ខ្លួនតែម្តង។

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] **ភីរុណ** បានឆ្លើយថា ៖ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ ប្រហែលម៉ោង ០៥ រសៀល ឈ្មោះ [redacted] **សុភ័ណ្ឌ** បានទូរស័ព្ទមកខ្លួន ដើម្បីឱ្យខ្លួនទៅចាំដីឈ្មោះ [redacted] **ហេង** មួយថ្ងៃពីរថ្ងៃ ដោយឱ្យថ្លៃឈ្នួលក្នុងមួយថ្ងៃ ៤០០០០រៀល។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ០៥ព្រឹក ខ្លួន, ឈ្មោះ [redacted] **សុភ័ណ្ឌ** និងឈ្មោះ [redacted] **ពុទ្ធា** បានជិះរថយន្តមកខេត្តព្រះសីហនុ។ ពេលធ្វើដំណើរតាមផ្លូវឈ្មោះ [redacted] **សុភ័ណ្ឌ** បានទូរស័ព្ទប្រាប់ឈ្មោះ **ចំណាន** ឱ្យទៅចាំជួបគ្នានៅទីតាំងដី។ វេលាម៉ោង ០៧ជាង ក៏មកដល់ទីតាំងដីហើយបានជួបឈ្មោះ **ចំណាន**, ឈ្មោះ [redacted] **រិទ្ធី**, ឈ្មោះ [redacted] **សុខុម** និងឈ្មោះ [redacted] **ឌៀ** ហើយឈ្មោះ [redacted] **សុភ័ណ្ឌ** បានប្រើខ្លួននិងឈ្មោះ [redacted] **រិទ្ធី**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **ឌៀ** ឱ្យទៅបើកទ្វាររបង ហើយខ្លួនក៏ដើរទាញទ្វារអង្រែនទ្វាររហូតដល់របើក។ បន្ទាប់មកពួកខ្លួនទាំង ០៧នាក់រួមមាន ខ្លួន, ឈ្មោះ [redacted] **ឌៀ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **សុភ័ណ្ឌ**, ឈ្មោះ [redacted] **រិទ្ធី** ហៅ **ស្វិត**, ឈ្មោះ [redacted] **ពុទ្ធា** និងឈ្មោះ **ចំណាន** បានដើរចូលទៅខាងក្នុងហើយបានឃើញបុគ្គលិកក្រុមហ៊ុនជាច្រើននាក់នៅទីនោះលុះវេលាម៉ោងប្រហែល ០៩ព្រឹកឈ្មោះ [redacted] **សុភ័ណ្ឌ** ឈ្មោះ [redacted] **ពុទ្ធា** និងឈ្មោះ **ចំណាន** បានបើករថយន្តចេញទៅវិញ។ ក្រោយមកមេការរបស់បុគ្គលិកក្រុមហ៊ុនបានមកដល់ហើយបានឱ្យបុគ្គលិកក្រុមហ៊ុននៅចាំឃាមពួកខ្លួនមិនឱ្យទៅណា រហូតដល់ម៉ោង១០ ក៏សមត្ថកិច្ចមកដល់ឃាត់ខ្លួន។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] **កញ្ញារិទ្ធិ** បានឆ្លើយថា ៖ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង០៦ និង៣០នាទី នៅចំណុចភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ឈ្មោះ [redacted] **ភីរុណ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **រិទ្ធី**, ឈ្មោះ [redacted] **ស្ល** និងបក្ខពួកបានមកដល់ទីតាំងដីរបស់ក្រុមហ៊ុនហួហាយ ហើយប្រាប់ថាមេរបស់ពួកគេឱ្យមកកាន់កាប់ដីខាងលើនេះ រួចគាត់ក៏ដេញពួកគេចេញពីទីតាំងដីក្រុមហ៊ុន ដោយប្រាប់ថាចាំជួបមេរបស់គាត់ទៅស្រាប់តែមានរថយន្តចំនួន ០២គ្រឿង ម៉ាក Ford Rapter F150 ពណ៌ស ពាក់ស្លាកលេខ2BP-3999 និងម៉ាក Vigo ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2AB-3060 មកឈប់នៅមុខទីតាំងដីក្រុមហ៊ុនរួចក៏មានមនុស្ស ០៤នាក់ ចុះពីលើរថយន្ត និងស្រែកបញ្ជាឱ្យឈ្មោះ [redacted] **ភីរុណ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **រិទ្ធី**, ឈ្មោះ [redacted] **ឌៀ**, ឈ្មោះ [redacted] **ស្ល** និងបក្ខពួក ទាញទ្វាររបងផ្តាច់សោរ បន្ទាប់ពីសោរត្រូវគេផ្តាច់បានក៏នាំគ្នាសម្រុកចូលមកក្នុងទីតាំងដី ព្រមទាំងស្រែកគំរាមអ្នកចាំដី និងខ្លួនថា ឱ្យចាកចេញពីទីតាំងដីនេះជាបន្ទាន់ ពេលនោះខ្លួនឃើញគ្នារបស់គេច្រើនពេក និងភ័យផងនោះក៏រាយការណ៍ប្តឹងសមត្ថកិច្ចតែម្តងទៅ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ជនរងគ្រោះ និងភស្តុតាងនានាដែលមានក្នុងសំណុំរឿងខាងលើឃើញថា ជនជាប់ចោទបានឆ្លើយសារភាពថា ពួកគេពិតជាបានរុញរបងទ្វាររបស់ក្រុមហ៊ុនហួហាយ ដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ ក្នុងគោលបំណងកាន់កាប់ជាកម្មសិទ្ធិ បើទោះបីជាមានការហាមឃាត់ពីសន្តិសុខរបស់ក្រុមហ៊ុនយ៉ាងណាក៏ដោយ។ ហេតុនេះតំណាងអយ្យការសន្និដ្ឋានបានថា ជនជាប់ចោទឈ្មោះ [redacted] **ភីរុណ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **រិទ្ធី**, ឈ្មោះ [redacted] **ឌៀ** និងឈ្មោះ [redacted] **សុភ័ណ្ឌ** ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ហេតុដូច្នេះស្នើសុំដល់ចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទខាងលើតាមច្បាប់។

-សេចក្តីសន្និដ្ឋានរបស់លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ៖ ក្រោយពីបានស្តាប់ចម្លើយរបស់កូនក្តីខ្លួន និងភស្តុតាងនានាឃើញថា កូនក្តីខ្លួនជាកម្មករសំណង់ដែលស្គាល់មេការឈ្មោះ [redacted] **សុភ័ណ្ឌ** ហើយនៅមុនពេលកើតហេតុឈ្មោះ **សុភ័ណ្ឌ** បានហៅកូនក្តីរបស់ខ្លួនទៅឃាមដី ដោយឱ្យប្រាក់ឈ្នួលក្នុង ០១ថ្ងៃ ៤ម៉ឺនរៀល ដោយមិនមានចេតនាយកមកធ្វើជាកម្មសិទ្ធិនោះទេ ហើយកូនក្តីខ្លួនមកទីតាំងកន្លែងកើតហេតុតាមរយៈឈ្មោះ [redacted] **សុភ័ណ្ឌ** តែប៉ុណ្ណោះ។ ហេតុនេះមិនមានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់ដាក់បន្ទុកលើកូនក្តីខ្លួនឈ្មោះ [redacted] **ភីរុណ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **រិទ្ធី** និងឈ្មោះ [redacted] **ឌៀ**។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ស្នើសុំលោកចៅក្រមមេត្តាពិនិត្យ និងសម្រេចឱ្យកូនក្តីខ្លួនរួចផុតបទចោទ។

-សេចក្តីសន្និដ្ឋានរបស់លោក [redacted] **សិរីវឌ្ឍនៈ** មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ៖ ខ្លួនឯកភាពតាមការសន្និដ្ឋានរបស់លោកមេធាវី [redacted] ខាងលើ។

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការប្តឹងសុំ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តព្រះសីហនុ

## យល់ឃើញថា

១.ជនជាប់ចោទឈ្មោះ [redacted] **ភីរុណ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **រិទ្ធី** និងឈ្មោះ [redacted] **ឌៀ** បានឆ្លើយប្រហាក់ប្រហែលគ្នាថា ៖ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ ឈ្មោះ [redacted] **សោភ័ណ្ឌ** បានហៅពួកខ្លួនទៅចាំដីឱ្យឈ្មោះ [redacted] **ហេង** ដោយឱ្យថ្លៃឈ្នួលក្នុងមួយថ្ងៃ ៤០០០០រៀល ហើយឈ្មោះ [redacted] **រិទ្ធី** និងឈ្មោះ [redacted] **ឌៀ** បានជិះម៉ូតូទៅទីតាំងដីកើតហេតុ ជួបអ៊ុំប្រុសម្នាក់ចាំទទួលពួកខ្លួន ហើយឈ្មោះ [redacted] **ឌៀ** បានត្រឡប់ទៅវិញ។ វេលាម៉ោង ០៦ល្ងាច បុគ្គលិកក្រុមហ៊ុនចំនួន ២០នាក់ បានដល់ទីតាំងដី ហើយបានដកយកសោទ្វាររបងពីអ៊ុំប្រុស ព្រមទាំងឱ្យពួកខ្លួនរើចេញពីទីនោះ។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង០៦ និង ៣០នាទីព្រឹក ឈ្មោះ [redacted] **សោភ័ណ្ឌ** បានទូរស័ព្ទមកកុំឱ្យចេញពីទីតាំងដី ហើយឈ្មោះ [redacted] **ឌៀ** និងឈ្មោះ [redacted] **សុខុម** ក៏បានជិះម៉ូតូមកដល់ លុះនៅម៉ោងប្រហែល ០៧ព្រឹក ឈ្មោះ [redacted] **សុភ័ណ្ឌ**, ឈ្មោះ [redacted] **ភីរុណ**, ឈ្មោះ [redacted] **ពុទ្ធា** និងឈ្មោះ **ចំណាន** បានមកដល់ទីតាំងដីហើយបានសុំឱ្យបុគ្គលិកក្រុមហ៊ុនបើកទ្វារតែគេថាចាំសុំមេគេសិន។ បន្ទាប់មកឈ្មោះ [redacted] **ភីរុណ** បានទៅអង្រួនទ្វាររបង់រហូតដល់របើកហើយពួកខ្លួនទាំង ០៧នាក់ រួមមាន [redacted] **រិទ្ធី**, ឈ្មោះ [redacted] **ឌៀ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **សុភ័ណ្ឌ** ឈ្មោះ [redacted] **ភីរុណ** ឈ្មោះ [redacted] **ពុទ្ធា** និងឈ្មោះ **ចំណាន** បានដើរចូលទៅខាងក្នុង។ វេលាម៉ោងប្រហែល ០៩ព្រឹក ឈ្មោះ [redacted] **សុភ័ណ្ឌ**, ឈ្មោះ [redacted] **ពុទ្ធា** និងឈ្មោះ **ចំណាន** បានបើករថយន្តចេញទៅ ក៏មានសមត្ថកិច្ចមកដល់ឃាត់ពួកខ្លួន (ឈ្មោះ [redacted] **ភីរុណ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **រិទ្ធី** និងឈ្មោះ [redacted] **ឌៀ**)។ ដែលចម្លើយរបស់ជនជាប់ចោទខាងលើមានភាពស៊ីសង្វាក់ទៅនឹងចម្លើយសាក្សីឈ្មោះ [redacted] **កញ្ញារិទ្ធិ** បានឆ្លើយថា ៖ នៅថ្ងៃកើតហេតុ ឈ្មោះ [redacted] **ភីរុណ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **រិទ្ធី**, ឈ្មោះ [redacted] **ស្វ** និងបក្ខពួកបានមកដល់ទីតាំងដីរបស់ក្រុមហ៊ុនហ្វូហាយ (ភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ) ហើយប្រាប់ថាមេរបស់ពួកគេឱ្យមកកាន់កាប់ដី ខ្លួនដេញពួកគេចេញ ដោយប្រាប់ថាចាំជួបមេរបស់ខ្លួនទៅ ស្រាប់តែមានរថយន្តចំនួន ០២គ្រឿង មកឈប់នៅមុខទីតាំងដី និងមានមនុស្ស ០៤នាក់ ចុះពីលើរថយន្ត និងស្រែកបញ្ជាឱ្យឈ្មោះ [redacted] **ភីរុណ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **រិទ្ធី**, ឈ្មោះ [redacted] **ឌៀ**, ឈ្មោះ [redacted] **ស្វ** និងបក្ខពួក ទាញទ្វាររបងផ្តាច់សោរ បន្ទាប់ពីសោត្រូវគេផ្តាច់បានក៏នាំគ្នាសម្រុកចូលមកក្នុងទីតាំងដី ព្រមទាំងស្រែកគំរាមអ្នកចាំដី និងខ្លួនថា ឱ្យចាកចេញពីទីតាំងដីនេះជាបន្ទាន់ ពេលនោះខ្លួនឃើញគ្នារបស់គេច្រើនពេក និងភ័យផងនោះក៏រាយការណ៍ប្តឹងសមត្ថកិច្ចតែម្តងទៅ។

២.តាមចម្លើយសាក្សីឈ្មោះ [redacted] **កញ្ញារិទ្ធិ** បានឆ្លើយថា ៖ ទីតាំងដីរបស់ក្រុមហ៊ុនហ្វូហាយ នៅចំណុចភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ ដែលចម្លើយរបស់សាក្សីខាងលើស្របទៅនឹងបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ព.ន០០១៦០៩, លេខព.ន ០០១៦០៥, លេខ ព.ន ០០១៦០០ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ១៩៩៦។

៣.តាមចម្លើយជនជាប់ចោទ សាក្សី និងភស្តុតាងនានាក្នុងសំណុំរឿង អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] **ភីរុណ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **រិទ្ធី**, ឈ្មោះ [redacted] **ឌៀ** និងឈ្មោះ [redacted] **សុភ័ណ្ឌ** ពិតជាបានធ្វើសកម្មភាព រុញទ្វាររបងបណ្តាលឱ្យខូចខាត ដើម្បីចូលទៅកាន់កាប់ដីដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនហ្វូហាយអ៊ិនវេសមិន ដែលសកម្មភាពរបស់ជនជាប់ចោទខាងលើ ត្រូវបានច្បាប់កំណត់ថាជាបទល្មើស **ជនប្រើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងធ្វើឱ្យខូចខាតដោយចេតនា** បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា២៥៣ នៃច្បាប់ភូមិបាល និងមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ។

៤.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ភីរុណ, ឈ្មោះ [redacted] សុខុម, ឈ្មោះ [redacted] រិទ្ធី, ឈ្មោះ [redacted] ឌៀ និងឈ្មោះ [redacted] សុភ័ណ្ឌ ធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម និងទ្រព្យសម្បត្តិរបស់អ្នកដទៃ ហើយជនជាប់ចោទមានស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន គប្បីតុលាការពិចារណាពីការផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ។

**៥.**មានភស្តុតាង និងធាតុផ្សំដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] **ភីរុណ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **រិទ្ធី**, ឈ្មោះ [redacted] **ឌៀ** និងឈ្មោះ [redacted] **សុភ័ណ្ឌ** ពីបទ ៖ **ប្រើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅចំណុចភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា២៥៣ នៃច្បាប់ភូមិបាល និងមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ។

**៦.**ជនជាប់ចោទឈ្មោះ [redacted] **ភីរុណ**, ឈ្មោះ [redacted] **សុខុម**, ឈ្មោះ [redacted] **រិទ្ធី**, និងឈ្មោះ [redacted] **ឌៀ** ត្រូវបានតុលាការកំពូលសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ហើយអំពើរបស់ជនជាប់ចោទ មិនបង្កព្យសនកម្មធ្ងន់ធ្ងរ ព្រមទាំងមិនដែលមានសាលក្រមសម្រេចផ្តន្ទាទោសជាស្ថាពរឱ្យជាប់ក្នុងពន្ធនាគាររយៈពេល ០៥ឆ្នាំ មុនពេលប្រព្រឹត្តអំពើខាងលើនេះ គប្បីតុលាការពិចារណាអំពីការព្យួរទោសលើជនជាប់ចោទខាងលើ តាមមាត្រា១០៦, មាត្រា១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

**៧.**វត្ថុតាងរួមមាន ទូរស័ព្ទចំនួន ០៤គ្រឿង ម៉ាកអ៊ីហ្វូ (ពណ៌សចំនួន ០១គ្រឿង, ពណ៌ប្រផេះចំនួន ០១គ្រឿង, ពណ៌ខៀវចំនួន ០១គ្រឿង និងពណ៌ខ្មៅចំនួន ០១គ្រឿង) ជាសម្ភារៈប្រើប្រាស់សម្រាប់ទាក់ទងគ្នាក្នុងការប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូសតាមបញ្ញត្តិមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ។

## <u>ហេតុដូច្នេះសម្រេច</u>

**១.ផ្តន្ទាទោសលើ ៖**

**១.១** ឈ្មោះ [redacted] **រិទ្ធី ហៅ ស្និត** ភេទប្រុស កើតឆ្នាំ១៩៨៤ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់)ខែ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារគិតចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ទោសសល់ពីនេះត្រូវព្យួរទោសទាំងស្រុង**

**១.២** ឈ្មោះ [redacted] **សុខុម** ភេទប្រុស កើតឆ្នាំ១៩៩៥ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់)ខែ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារគិតចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ទោសសល់ពីនេះត្រូវព្យួរទោសទាំងស្រុង**

**១.៣** ឈ្មោះ [redacted] **ឌៀ** ភេទប្រុស កើតឆ្នាំ១៩៨៧ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់)ខែ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារគិតចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ទោសសល់ពីនេះត្រូវព្យួរទោសទាំងស្រុង**

**១.៤** ឈ្មោះ [redacted] **ភីរុណ** ភេទប្រុស កើតឆ្នាំ១៩៧២ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់)ខែ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារគិតចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ទោសសល់ពីនេះត្រូវព្យួរទោសទាំងស្រុង**

**១.៥** ឈ្មោះ [redacted] **សុភ័ណ្ឌ** ភេទប្រុស កើតឆ្នាំ១៩៨០ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់)ខែ**

ពីបទ៖ **ប្រើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅចំណុចភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា២៥៣ នៃច្បាប់ភូមិបាល និងមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ។

**២.រឹបអូសវត្ថុតាងរួមមាន** ៖ ទូរស័ព្ទចំនួន ០៤គ្រឿង ម៉ាកអ៊ីហ្វូ (ពណ៌សចំនួន ០១គ្រឿង, ពណ៌ប្រផេះចំនួន ០១គ្រឿង, ពណ៌ខៀវចំនួន ០១គ្រឿង និងពណ៌ខ្មៅចំនួន ០១គ្រឿង) តាមបញ្ញត្តិមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃច័ន្ទ ១១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃពុធ ៤រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ ចាត់ទុកចំពោះមុខជនជាប់ចោទឈ្មោ[redacted] ឌៀ, ឈ្មោះ [redacted] រិទ្ធី, និងឈ្មោះ[redacted] **សុខុម** និងកំបាំងមុខជនជាប់ចោទឈ្មោះ[redacted] **ភីរុណ** និងឈ្មោ[redacted] **សុភ័ណ្ឌ**។

ទុកសិទ្ធិឱ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍នៅក្នុងកំណត់ច្បាប់៕

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និងត្រា ÷** [redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា ÷** [redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
**ថ្ងៃពុធ ៤រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥**
**ខេត្តព្រះសីហនុ, ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២**
**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
**ចៅក្រម**

[redacted]